មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
# គោលការណ៍ស្ដីពីបរិស្ថាន

ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

# គោលការណ៍ស្តីពីបរិស្ថាន

## ១. សេចក្តីផ្តើម

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ប្តេជ្ញាកាត់បន្ថយសកម្មភាពទាំងឡាយរបស់ខ្លួនដែលបង្កផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន ព្រមទាំងលើកទឹកចិត្តដល់បុគ្គលផ្សេងៗក្នុងសហគមន៍របស់យើងឱ្យកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានផងដែរ។ គោលការណ៍ស្តីពីបរិស្ថាននេះ ណែនាំអំពីវិធីនានាដែល ម.ស.ម.ក នឹងបំពេញទៅតាមការប្តេជ្ញានេះ។ បុគ្គលិកគ្រប់រូបមានទំនួលខុសត្រូវក្នុងការអនុវត្តគោលការណ៍នេះ និងកាត់បន្ថយសកម្មភាពរបស់ខ្លួនដែលបង្កផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន។ ទំនួលខុសត្រូវប្រចាំថ្ងៃដើម្បីធានាថាគោលការណ៍នេះត្រូវបានអនុវត្តដោយប្រសិទ្ធភាព ត្រូវប្រគល់ជូនប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល ដែលនឹងត្រូវសហការយ៉ាងស្និទ្ធជាមួយក្រុមការងាររដ្ឋបាល ក្រុមការងារគម្រោងនិងគណៈកម្មាធិការលទ្ធកម្មដើម្បីអនុវត្តគោលការណ៍នេះទៅក្នុងសកម្មភាពការងារជាក់ស្តែង។

## ២. ការប្តេជ្ញាក្នុងការអនុវត្តបេសកកម្ម

ម.ស.ម.ក ប្តេជ្ញាអភិវឌ្ឍខ្លួនក្លាយទៅជាស្ថាប័នឈានមុខគេក្នុងការបន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាននៅក្នុងសហគមន៍មូលដ្ឋាន និងបង្កើតផលជះវិជ្ជមានទៅលើបរិស្ថានតាមរយៈការបង្កើត និងការអនុវត្តគោលការណ៍បៃតងប្រកបដោយប្រសិទ្ធភាព។ ម.ស.ម.ក ទទួលស្គាល់ថា ស្ថាប័នមានទំនួលខុសត្រូវចំពោះបរិស្ថានហួសពីលក្ខខណ្ឌដែលច្បាប់និងបទប្បញ្ញត្តិតម្រូវ ហើយការបង្កើតបរិយាកាសមានស្ថិរភាពនិងសុខភាពល្អ គឺជាកត្តាចាំបាច់នាំឱ្យមានការគោរពសិទ្ធិមនុស្សពេញលេញនៅគ្រប់វិស័យ។ ម.ស.ម.ក ប្តេជ្ញាក្នុងការកាត់បន្ថយសកម្មភាពដែលជះឥទ្ធិពលអវិជ្ជមានទៅលើបរិស្ថាន និងបន្តពង្រឹងការអនុវត្តគោលការណ៍បរិស្ថានរបស់យើង ដែលជាផ្នែកសំខាន់មួយនៃការបំពេញការងាររបស់យើងក្នុងនាមជាអង្គការសង្គមស៊ីវិល។ ម.ស.ម.ក នឹងជំរុញរាជរដ្ឋាភិបាលកម្ពុជា បុគ្គលនានា សហគមន៍របស់យើង អង្គការសង្គមស៊ីវិលផ្សេងទៀត និងធុរកិច្ចអនុវត្តដូចគ្នាផងដែរ។

## ៣. ច្បាប់

ម.ស.ម.ក នឹងបំពេញតាមច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលការណ៍ដែលមានភាពអំណោយផលដល់បរិស្ថាន ទាំងច្បាប់កំពុងមានជាធរមាន និងច្បាប់ដែលត្រូវអនុម័តនៅពេលអនាគតបន្ទាប់ពីការចេញផ្សាយគោលការណ៍នេះ។

## ៤. វិសាលភាពនៃគោលការណ៍

គោលការណ៍នេះអនុវត្តចំពោះបុគ្គលិក ម.ស.ម.ក ទាំងអស់ ដូចមានចែងក្នុងគោលការណ៍ស្តីពីការងារ ក្នុងនោះ រួមមាន ទីប្រឹក្សា អ្នកហាត់ការនិងអ្នកស្ម័គ្រចិត្ត។ គោលការណ៍នេះអនុវត្តនៅក្នុងការិយាល័យ ម.ស.ម.ក ព្រមទាំងនៅពេលបុគ្គលិកបំពេញតួនាទីជាតំណាង ម.ស.ម.ក ក្នុងសមាសភាពផ្លូវការនៅខាងក្រៅការិយាល័យ រួមទាំង

នៅពេលប្រជុំជាមួយភាគីពាក់ព័ន្ធ អ្នកទទួលផល ហើយនិងការចុះបំពេញបេសកកម្មផងដែរ។ ម្យ៉ាងទៀត ម.ស.ម.ក ស្នើដោយទទូចដល់បុគ្គលិកទាំងអស់ ត្រូវមានស្មារតីប្រុងប្រយ័ត្នចំពោះសកម្មភាពផ្ទាល់ខ្លួនដែលបង្កផលប៉ះពាល់ដល់បរិស្ថាននៅខាងក្រៅការិយាល័យ។

## ៥. ផែនការអនុវត្ត

ម.ស.ម.ក នឹងចាត់វិធានការខាងក្រោមដើម្បីអនុវត្តតាមការប្តេជ្ញាចិត្តផ្នែកបរិស្ថានរបស់ខ្លួន៖

### ៥.១ ការវាយតម្លៃ និងការយល់ដឹង

ម.ស.ម.ក នឹងវាយតម្លៃប្រតិបត្តិការរបស់ខ្លួនឱ្យបានជាប់លាប់ដើម្បីធានាថាប្រតិបត្តិការនិងការអនុវត្តប្រចាំថ្ងៃរបស់ស្ថាប័នមាននិរន្តរភាពនិងប្រសិទ្ធភាពទៅតាមលទ្ធភាព និងធានាថាបុគ្គលិកមានការយល់ដឹងអំពីផលប៉ះពាល់បរិស្ថាន។ ម.ស.ម.ក ប្តេជ្ញាក្នុងការបង្កើនចំណេះដឹងផ្នែកបរិស្ថាននិងបន្តតាមដានលើការវិវឌ្ឍផ្នែកច្បាប់ដែលមានថ្មីៗ និងការវិវឌ្ឍផ្នែកវិទ្យាសាស្ត្រថ្មីៗ ដើម្បីកែប្រែឥរិយាបថរបស់ខ្លួននិងការបណ្តុះបណ្តាលនានាស្របតាមព័ត៌មានថ្មីៗ។

### ៥.២ ការបំភាយ

ម.ស.ម.ក នឹងកាត់បន្ថយការបំភាយជាតិពុល តាមរយៈការជ្រើសរើសនិងការប្រើប្រាស់យានយន្តរបស់ខ្លួន។ បុគ្គលិកត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈឬការរួមដំណើរយានជំនិះជាមួយបុគ្គលិកផ្សេងទៀតទៅតាមលទ្ធភាព ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន។

ម.ស.ម.ក នឹងអនុវត្តសកម្មភាពកាបូនឌីអុកស៊ីត នោះគឺសកម្មភាពទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលសាយភាយទៅក្នុងបរិយាកាស ដើម្បីប៉ះប៉ូវចំពោះការបំភាយឧស្ម័នដែលកើតចេញពីសកម្មភាពរបស់ ម.ស.ម.ក នៅគ្រប់ទីកន្លែង ដូចជា ការដឹកជញ្ជូន ឬការប្រើប្រាស់អគ្គិសនីជាដើម។ ក្នុងនេះយ៉ាងហោចណាស់ ម.ស.ម.កចូលរួមសកម្មភាពមួយចំនួនដូចជាតាមរយៈការដាំដើមឈើនៅពេលកម្មវិធីជួបប្រជុំបុគ្គលិកប្រចាំឆ្នាំ ការដាវកាបូនឌីអុកស៊ីតតាមរយៈសំបុត្រយន្តហោះសម្រាប់បុគ្គលិកធ្វើដំណើរក្នុងគោលបំណងបំពេញការងារជាដើម។

### ៥. ៣. ការកាត់បន្ថយកាកសំណល់

ម.ស.ម.ក នឹងព្យាយាមកាត់បន្ថយនូវកាកសំណល់ ហើយនិងលើកកម្ពស់យ៉ាងសកម្មដល់ការកែច្នៃឡើងវិញទាំងនៅខាងក្នុងស្ថាប័ននិងក្នុងចំណោមក្រុមហ៊ុនផ្គត់ផ្គង់សេវារបស់ខ្លួន។ ម.ស.ម.ក នឹងអនុវត្តវិធីដែលអាចឱ្យបុគ្គលិកកែច្នៃក្រដាស ប្លាស្ទិក និងកាកសំណល់កញ្ចក់ ហើយនិងវិធីច្នៃផលិតកាកសំណល់អាហារទៅជាជីកំប៉ុស្តិ៍។

**លើសពីនេះទៀត:**

- បុគ្គលិកទាំងអស់គួរតែកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកដែលប្រើតែម្តងរួចបោះចោលនៅក្នុងការិយាល័យ គោលបំណងចម្បងនោះគឺការលុបបំបាត់ប្លាស្ទិកដែលប្រើតែម្តងរួចបោះចោលគ្រប់ប្រភេទ និងលើកទឹកចិត្តជាខ្លាំងឱ្យបុគ្គលិកប្រើប្រាស់សម្ភារៈដែលអាចកិនកម្ទេចទៅជាសារធាតុរាវបាន អាចកែច្នៃបាន ឬអាចប្រើឡើងវិញបានទៅតាមលទ្ធភាព។ ប្លាស្ទិកដែលប្រើតែម្តងរួចបោះចោលមានច្រើនប្រភេទ ដូចជា បំពង់បឺតប្លាស្ទិក ដបប្លាស្ទិក ពែង ឬ កែវប្លាស្ទិក ប្រអប់វេចខ្ចប់ចំណី-អាហារប្លាស្ទិក ធុងនិងថង់ប្លាស្ទិកជាដើម។ល។
- បុគ្គលិកទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការរក្សាទុក/ការបោះចោលសំរាមប្រកបដោយទំនួលខុសត្រូវ ដោយពុំត្រូវបោះចោលដោយគ្មានសណ្តាប់ធ្នាប់ឡើយ
- បុគ្គលិកត្រូវប្រើប្រាស់បច្ចេកវិទ្យាថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពទៅតាមពេលវេលាសមស្រប ដូចជា ការប្រើអំពូលភ្លើងថាមពលអគ្គិសនីជាដើម
- បុគ្គលិកត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះបរិស្ថាន ជាពិសេសនៅពេលព្រីនឯកសារ និងត្រូវព្យាយាមកាត់បន្ថយការប្រើប្រាស់ក្រដាសស្អាត និងការព្រីននៅការិយាល័យទៅតាមលទ្ធភាព ព្រមទាំងត្រូវប្រើក្រដាសសំណល់សម្រាប់ឯកសារមិនផ្លូវការជាដើម
- ម.ស.ម.ក នឹងវាយតម្លៃពីផលប៉ះពាល់បរិស្ថានលើផលិតផលដែលខ្លួនត្រូវជាវ និងព្យាយាមគាំទ្រនូវផលិតផលទាំងឡាយណាដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថានទៅតាមលទ្ធភាព ហើយ
- ម.ស.ម.ក នឹងគាំទ្រធុរកិច្ចក្នុងស្រុកដែលធ្វើសកម្មភាពមិនបង្កផលប៉ះពាល់ដល់បរិស្ថានទៅតាមលទ្ធភាព។

## ៥.៤ ការបណ្តុះបណ្តាល

ម.ស.ម.ក នឹងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួនដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថាននិងស្នើឱ្យបុគ្គលិកចូលរួមក្នុងការកែលម្អការអនុវត្តរបស់ ម.ស.ម.ក ក្នុងវិស័យនេះ យ៉ាងហោចណាស់ឱ្យបានពីរដងក្នុងមួយឆ្នាំ។ ការបណ្តុះបណ្តាលនឹងបញ្ចូលទាំងការអនុវត្តដូចបានបញ្ជាក់ខាងលើ ដូចជា វិធីកែច្នៃកាកសំណល់ឡើងវិញ ការកំណត់ជ្រើសរើសយកសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញបាន ឬអាចបំប្លែងទៅជាសាធារជាតុរាវបាន និងការបំភាយកាបូនឌីអុីស៊ីតជាដើម។ នៅក្នុងកម្មវិធីធំៗដែលមានការចូលរួមពីបុគ្គលិកទាំងអស់ ដូចជា កម្មវិធីប្រជុំបុគ្គលិកប្រចាំឆ្នាំ ឬសិក្ខាសាលារៀបចំផែនការយុទ្ធសាស្ត្រជាដើម ត្រូវបញ្ចូលកិច្ចពិភាក្សាអំពីបរិស្ថាននិងវិធីកាត់បន្ថយផលប៉ះពាល់បរិស្ថានទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំទាំងនោះ។ ក្នុងពេលវេលាសមគួរណាមួយ បុគ្គលិក ម.ស.ម.ក អាចចូលរួមវគ្គបណ្តុះបណ្តាលនានាដើម្បីបង្កើនការយល់ដឹងអំពីបរិស្ថានរៀបចំឡើងដោយស្ថាប័នផ្សេងទៀត។ នៅពេលចុះបំពេញការងារនៅតាមមូលដ្ឋាន ម.ស.ម.ក នឹងផ្សព្វផ្សាយគោលនយោបាយបរិស្ថានរបស់ខ្លួននិងជួយអប់រំសហ

គមន៍មូលដ្ឋានអំពីសារៈសំខាន់នៃការកាត់បន្ថយកាកសំណល់និងផលប៉ះពាល់ចំពោះសហគមន៍របស់ពួកគេក្នុងកម្មវិធីពាក់ព័ន្ធ។

## ៥.៤. ការតស៊ូមតិ

ម.ស.ម.ក នឹងចូលរួមក្នុងការតស៊ូមតិទាក់ទងនឹងបរិស្ថានដែលពាក់ព័ន្ធនឹងអាណត្តិការងាររបស់ខ្លួន និងចូលរួមតស៊ូមតិដើម្បីការពារអ្នកការពារសិទ្ធិមនុស្សនិងអង្គការផ្នែកបរិស្ថាននៅកម្ពុជា។ បុគ្គលិករបស់ ម.ស.ម.ក ត្រូវលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថាននៅពេលអនុវត្តការងារជាមួយអ្នកទទួលផលតាមលទ្ធភាពដែលអាចធ្វើទៅបាននិងក្នុងកម្មវិធីដែលពាក់ព័ន្ធ។